ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ
លេខ .....

ថ្ងៃ.....ខែ.....ឆ្នាំកុរ ឯកស័ក ព.ស.២៥៦៣
រាជធានីភ្នំពេញ ថ្ងៃទី.....ខែ.....ឆ្នាំ២០

សូមគោរពជូន
ឯកឧត្តមរដ្ឋមន្ត្រីក្រសួងបរិស្ថាន

ម្ចាស់គម្រោង តំណាងដោយ **ឯកឧត្តម ស៊ឹម ស៊ីថា** ជាអគ្គនាយកនៃរដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ ដែលមានអាសយដ្ឋានស្ថិតនៅផ្ទះលេខ៤៥ ផ្លូវ១០៦ សង្កាត់ស្រះចក ខណ្ឌដូនពេញ រាជធានីភ្នំពេញ។

សូមធ្វើកិច្ចសន្យាការពារបរិស្ថាន

ដើម្បីរួមចំណែកធានានូវនិរន្តរភាពបរិស្ថានក្នុងកិច្ចដំណើរការអភិវឌ្ឍប្រទេសជាតិ ខ្ញុំសូមធ្វើកិច្ចសន្យាការពារបរិស្ថានចំពោះក្រសួងបរិស្ថាន សម្រាប់គម្រោងពង្រីកប្រព័ន្ធផ្គត់ផ្គង់ទឹកស្អាតក្រុងតាខ្មៅ លើផ្ទៃដីទំហំ ៤.៥៣៦ម៉ែត្រការ៉េ (បួនពាន់ប្រាំរយសាមសិបប្រាំមួយម៉ែត្រការ៉េ) ដែលមានទីតាំងស្ថិតនៅភូមិដើមមៀន សង្កាត់ដើមមៀន ក្រុងតាខ្មៅ ខេត្តកណ្តាល របស់រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ (ម្ចាស់គម្រោង) តាមប្រការដូចខាងក្រោម៖

ប្រការ១.-

ធានាទទួលខុសត្រូវ និងអនុវត្តនូវខ្លឹមសារដែលបានរៀបរាប់នៅក្នុងរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថាន និងសង្គមដំបូង (IESIA) សម្រាប់គម្រោងពង្រីកប្រព័ន្ធផ្គត់ផ្គង់ទឹកស្អាតក្រុងតាខ្មៅ ដែលក្រសួងបរិស្ថានបានឯកភាព។

ប្រការ២.-

ធានាផ្តល់របាយការណ៍អង្កេតតាមដានបរិស្ថាន (Environmental Monitoring Report) រៀងរាល់ ០៦ខែម្តង នៅក្នុងកិច្ចដំណើរការសាងសង់ និងប្រតិបត្តិគម្រោងជូនក្រសួងបរិស្ថាន ដើម្បីពិនិត្យ និងវាយតម្លៃ។

ប្រការ៣.-

ធានាផ្តល់របាយការណ៍សង្ខេបនៃការសិក្សាលម្អិត (Summary Detailed Design Report) សម្រាប់គម្រោងពង្រីកប្រព័ន្ធផ្គត់ផ្គង់ទឹកស្អាតក្រុងតាខ្មៅ ដែលមិនបានលម្អិតនៅក្នុងរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថាន និងសង្គមដំបូង (IESIA) ដើម្បីដាក់ជូនក្រសួងបរិស្ថានពិនិត្យ និងផ្តល់យោបល់។

ប្រការ៤.-

ក្នុងករណីក្រសួងបរិស្ថានតម្រូវឱ្យម្ចាស់គម្រោងធ្វើការកែប្រែនូវបច្ចេកទេសបរិស្ថានណាមួយ ដើម្បីឱ្យសមស្របទៅតាមគោលការណ៍ណែនាំ និងកម្រិតបទដ្ឋានបរិស្ថានម្ចាស់គម្រោងនឹងទទួលអនុវត្តទៅតាមគោលការណ៍ណែនាំនោះទាំងស្រុង។

ប្រការ៥.-

ទៅថ្ងៃអនាគត បើម្ចាស់គម្រោងមានគម្រោងពង្រីកបន្ថែម ឬផ្លាស់ប្តូរ ឬកែសម្រួលរបាយការណ៍សិក្សាសមទ្ធិលទ្ធភាព (Feasibility Study Report) ឬផ្អាកសកម្មភាព ម្ចាស់គម្រោងនឹងរាយការណ៍ជូនក្រសួងបរិស្ថានឱ្យបានមុន ០១ខែ។

ប្រការ៦.-

អនុញ្ញាតឱ្យមន្ត្រីជំនាញពីក្រសួងបរិស្ថាន ឬមន្ទីរបរិស្ថានខេត្តកណ្តាល ដែលមានលិខិតបញ្ជាបេសកកម្មត្រឹមត្រូវ ដើម្បីធ្វើការត្រួតពិនិត្យនៅទីតាំងតំបន់គម្រោង។

ប្រការ៧.-

ក្នុងករណីដែលម្ចាស់គម្រោងពុំបានគោរពតាមប្រការណាមួយ ឬអនុវត្តផ្ទុយពីកិច្ចសន្យានេះ ឬលិខិតបទដ្ឋានគតិយុត្តចូលជាធរមានផ្សេងៗទៀត ម្ចាស់គម្រោងនឹងទទួលខុសត្រូវចំពោះមុខច្បាប់ជាធរមាន។

អគ្គនាយក

ស៊ឹម ស៊ីថា

បានឃើញ និងគោរពជូន
ឯកឧត្តមរដ្ឋមន្ត្រីក្រសួងបរិស្ថាន មេត្តាពិនិត្យ និងសម្រេច
លេខ៖ ៤២៨ វ.ហ.ប.ស្ត
ថ្ងៃសុក្រ ៥កើត ខែ ៨ឆ្នូន ឆ្នាំកុរ ឯកស័ក ព.ស.២៥៦៣
រាជធានីភ្នំពេញ ថ្ងៃទី ១៣ ខែ មីនា ឆ្នាំ២០២០
ប្រធាននាយកដ្ឋានទាយតម្លៃហេតុប៉ះពាល់បរិស្ថាន

ជាញ់-សេរី

បានឃើញ និងឯកភាព
ថ្ងៃព្រហស្បតិ៍ ១១កើត ខែ ៨ឆ្នូន ឆ្នាំកុរ ឯកស័ក ព.ស.២៥៦៣
រាជធានីភ្នំពេញ ថ្ងៃទី ១៩ ខែ មីនា ឆ្នាំ២០២០
ជ.រដ្ឋមន្ត្រីក្រសួងបរិស្ថាន
រដ្ឋលេខាធិការ

សៅ-សុភាព